ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......សហវ.

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ　　　　　រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៦ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ០៤២ កយ.ពណ.ប្រក/២៣ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ ស្តីពីនីតិវិធីនៃការពិន័យអន្តរការណ៍ លើអំពើល្មើសពាក់ព័ន្ធនឹងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

ការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ត្រូវបានរៀបចំជាបញ្ជីផាកពិន័យ ដោយអនុលោមតាមមាត្រា៣៤ មាត្រា៣៦ មាត្រា៣៧ និងមាត្រា៣៨ នៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ។ បញ្ជីផាកពិន័យនេះ មានបរិយាយអំពីប្រភេទអំពើល្មើស និងកម្រិតទឹកប្រាក់ផាកពិន័យទៅតាមប្រភេទអំពើល្មើសនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ២ .–**

ចំណូលប្រមូលបានពីការពិន័យអន្តរការណ៍ និងការផ្តន្ទាទោសពិន័យជាប្រាក់ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ត្រូវកត់ត្រាជាចំណូលរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ៣ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ខែ ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**បញ្ជីផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ**

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | | មាត្រានៃច្បាប់ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ (រៀល) | |
|---|---|---|---|---|---|
| | | | | អប្បបរមា | អតិបរមា |
| | ១- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលដំណើរការអាជីវកម្មម្ហូបអាហារដោយមិនមានលិខិតអនុញ្ញាត | | | |
| ១ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ២ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ២- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលរៀបចំ ស្តុកទុក ធ្វើសហគ្គករណ៍ ឬលក់ម្ហូបអាហារដែលខូះអនាម័យ | | | |
| ៣ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ៤ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ៣- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលមិនបានជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ | | | |
| ៥ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ៦ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ៤- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលមិនបានបង្កើត ឬអនុវត្តប្រព័ន្ធដែលអាចអង្កេតដាន | | | |
| ៧ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ៨ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ៥- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយមិនមានបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករ និង/ឬអ្នកចែកចាយម្ហូបអាហារ | | | |
| ៩ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ១០ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | | មាត្រានៃច្បាប់ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ (រៀល) | |
|---|---|---|---|---|---|
| | | | | អប្បបរមា | អតិបរមា |
| | ៦- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារដែលមិនមានដាក់កាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់ | | | |
| ១១ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ១២ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ៧- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលផ្គត់ផ្គង់ លក់ដុំ ចែកចាយ ឬដាក់លក់ម្ហូបអាហារក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់ | | | |
| ១៣ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ១៤ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ៨- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលមិនបានគោរពតាមវិធានអនាម័យ ដែលត្រូវកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ | | | |
| ១៥ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ១៦ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ៩- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលមិនបានផ្តល់ព័ត៌មានអំពីខ្លឹមសារដែលបញ្ជាក់ពីគុណភាព សុវត្ថិភាពនៃម្ហូបអាហារ ដែលនឹងត្រូវផ្សាយដំណឹងពាណិជ្ជកម្ម | | | |
| ១៧ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ១៨ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ១០- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលមិនបានគោរពតាមការណែនាំ និងការកែតម្រូវរបស់មន្ត្រីអធិការកិច្ចម្ហូបអាហារ | | | |
| ១៩ | | - ផាកពិន័យលើកទី១ | មាត្រា៣៤ | ៥០០.០០០ | ៨.០០០.០០០ |
| ២០ | | - ផាកពិន័យលើកទី២ | មាត្រា៣៤ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | | មាត្រានៃច្បាប់ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ (រៀល) | |
|---|---|---|---|---|---|
| | | | | អប្បបរមា | អតិបរមា |
| | ១១- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារដែលបញ្ញត្តិក្នុងមាត្រា៦ | | | |
| ២១ | | - ជាកពិន័យលើកទី១ | មាត្រា៣៦ | ២.០០០.០០០ | ២០.០០០.០០០ |
| ២២ | | - ជាកពិន័យលើកទី២ | មាត្រា៣៦ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ១២- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលផ្សាយពាណិជ្ជកម្ម ឬធ្វើឱ្យមានការផ្សាយពាណិជ្ជកម្មដែលមិនពិត ឬធ្វើឱ្យយល់ខុស ឬធ្វើឱ្យមានការភាន់ច្រឡំអំពីលក្ខណៈពិតនៃម្ហូបអាហារ | | | |
| ២៣ | | - ជាកពិន័យលើកទី១ | មាត្រា៣៧ | ៥.០០០.០០០ | ១០.០០០.០០០ |
| ២៤ | | - ជាកពិន័យលើកទី២ | មាត្រា៣៧ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |
| | ១៣- | ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលដាក់ស្លាកសញ្ញាម្ហូបអាហារដែលមានលក្ខណៈមិនពិតធ្វើឱ្យយល់ខុស ឬក្លែងបន្លំ អំពីលក្ខណៈពិតនៃម្ហូបអាហារ | | | |
| ២៥ | | - ជាកពិន័យលើកទី១ | មាត្រា៣៨ | ១០.០០០.០០០ | ២០.០០០.០០០ |
| ២៦ | | - ជាកពិន័យលើកទី២ | មាត្រា៣៨ | ទ្វេដង នៃប្រាក់ពិន័យលើកទី១ | |